សម្លេងខ្មែរនៅបរទេស

# មហិច្ឆតាមិនចេះស្កប់ស្កល់របស់ម៉ូនិក!

ដោយលី-ឡៀប ★ ថ្ងៃទី២៩ ធ្នូ ២០០៤

បើយើងក្រឡេកមើលជីវប្រវត្តិរបស់ Paule Monique IZZI យើងពុំដឹងថា នាងមានសញ្ជាតិជាអ្វីពិតប្រាកដទេ ។ យើងគ្រាន់តែដឹងថា នាងមានឪពុកឈ្មោះ Jean-François IZZI ជាជនជាតិបារាំងដើមកំណើតអ៊ីតាលី និងមានម្តាយឈ្មោះ Pomme PEANG (កូនស្រីរបស់លោកស័ក្តិបីអ៊ុំ) ។ កំណើតថ្ងៃទី១៨ មិថុនា ១៩៣៦ ។ គ្មានទីកន្លែងកំណើត ។ ក្នុងប្រវត្តិរូបចុះផ្សាយនៅទំព័រ<វ៉ែបសាយ>របស់លោកសីហនុ សរសេរថា នាងបានរៀបការជាមួយលោកសីហនុ «ខែមេសា ឆ្នាំ១៩៥២» តែនៅក្នុងសៀវភៅ «ព្រះរាជវង្សានុវង្សនៃព្រះរាជាណាចក្រកម្ពុជា» សរសេរដោ-យលោក Justin J. Corfield បញ្ជាក់ថា នាងរៀបការជាមួយលោកសី-ហនុ «ថ្ងៃទី៥ ខែមិនា ឆ្នាំ១៩៥៥» ។ បើគេយកខែមេសាឆ្នាំ១៩៥២ តាម <វ៉ែបសាយ> ប្រហែលដែរ ពីព្រោះទ្រង់នរោត្តម-សីហមុនីកើតនៅថ្ងៃទី ១៤ ខែឧសភា ឆ្នាំ១៩៥៣ ។ ឆ្ងល់ថា បើមានពិធីរៀបការមែន ចុះហេតុអ្វីបានជាគ្មានថ្ងៃ ? ។ តែបើយកតាមលោក Corfield ឃើញថាដូចជាពុំត្រឹមត្រូវទេ ពីព្រោះថ្ងៃទី៥ ខែមិនា ឆ្នាំ១៩៥៥ គឺជាថ្ងៃឡើងគ្រងរាជ្យរបស់ឪពុកលោកសីហនុ (ទ្រង់នរោត្តម-សុរាម្រិត) ។ ហើយបើប្រសិន នាងនិងលោកសីហនុរៀបការនៅឆ្នាំ១៩៥៥មែននោះ គឺមានន័យថាអ្នកទាំ-ងពីរយកគ្នារហូតដល់មានកូនពីរ ទើបបានរៀបការជាក្រោយ ។

នៅក្នុងប្រវត្តិរូបរបស់លោកសីហនុ ដែលចុះនៅក្នុង<វ៉ែបសាយ> ក៏ដូចគ្នាក្នុងសៀវភៅរបស់លោក Corfield និងសៀវភៅរបស់លោក Raoul M. JENNAR ដែរ គេរកមិនឃើញមានការបញ្ជាក់ឲ្យដឹងថាលោ-កសីហនុបានរៀបការពេញច្បាប់ជាមួយប្រពន្ធណាមួយសោះ សូម្បីតែជាមួយ Paule Monique IZZI ដែលគេបានអះអាងថា ជាប្រពន្ធទី៦នេះក៏ដោយ ។

យើងលើកប្រវត្តិរូបសង្ខេបរបស់ Paule Monique IZZI មកបង្ហា-ញ គឺដើម្បីបញ្ជាក់ថា នាងពុំពិតជា«ខ្មែរ»ទេ ទាំងឈ្មោះនិងទាំងរូបរាង។ ចាប់តាំងពីបានជួបប្រសព្វជាមួយលោកសីហនុពេលណាមក (?!) ន-យោបាយស្រុកខ្មែរក៏ចាប់ផ្តើមងាកបន្តិចម្តងៗទៅរកកុម្មុយនិស្ត ជាពិសេសងាកទៅរកយួន ។ ភ្លើងសង្គ្រាមរាជវាំងក៏បានចាប់ផ្តើមឆាបឆេះដែររហូតដល់ទៅមានការបែងចែកគ្នា រវាង«វាំងចតុមុខ»និង«វាំងចំការមន» ជាដើម ។ ទំនាក់ទំនងរវាងម្តាយក្មេក (ម្តាយរបស់លោកសីហនុ) និងកូនប្រសារស្រី (អ្នកម្នាងម៉ូនិក) បានប្រែក្លាយទៅជាគូសត្រូវយ៉ាងជូរចត់ក្រៃលែង ។

អ្នកម្នាងម៉ូនិក ដោយមានម្តាយគឺយាយប៉ោម-ពាងជាទីប្រឹក្សា គ្រួសារខាងស្រីនេះបានពង្រីកឥទ្ធិពលរបស់ខ្លួន ចាក់ឫសស្ទើរគ្រប់សរសៃសរស្ទង់នៃរដ្ឋបាលជាតិ ដោយបង្កើតឲ្យមាន«អំពើពុករលួយ»លក់ជាតិ លួចជាតិ វត់ពន្ធ និង ការបង្កើតបនកាស៊ីណូជាដើម ។ សកម្មភាពដ៏អាស្រូវ បានត្រូវប្រជាពលរដ្ឋខ្មែរឃើញជាទូទៅនៅក្នុងអំឡុងឆ្នាំ១៩៦០ គឺនៅពេលលោកសីហនុអនុវត្តនយោបាយគាំទ្រពួកយួនយៀកកុង-យៀកណាមខាងជើង ឲ្យតាំងមូលដ្ឋានទ័ពនៅក្នុងទឹកដីខ្មែរតាមបណ្តោយព្រំដែនទិសខាងកើតប្រទេស គឺជាពេលដែលលោកសីហនុកំពុងងប់ងល់ជាមួយចម្រៀងភ្លេងភ្លាត់ដើរថតកុនយ៉ាងវក់វី ។ ទីកន្លែងណាដែលមានក្លិនស្អុយគគ្រុក គេតែងប្រទះឃើញនូវស្នាមមេដៃគ្រួសាររបស់អ្នកម្នាងនិងក្លូវរបស់គាត់ យ៉ាងក្រឡៀ និងចេញមុខប្រព្រឹត្តយ៉ាងគឃ្លើន ។

យើងចង់មានន័យថា ជោគជ័យនៃនយោបាយ«សង្គមរាស្ត្រនិយម» របស់លោកសីហនុទាំងប៉ុន្មាន បានមកត្រូវអ្នកម្នាងម៉ូនិកនិងក្លូវរបស់គាត់បំផ្លាញម៉ដ្ឋឡេវអស់រលីង ។ គឺដូចគ្នានឹងការរៀបចំស្រុកខ្មែរ ឲ្យរមៀលធ្លាក់ទៅក្នុងមហន្តរាយក្នុងទសវត្សឆ្នាំ៧០យ៉ាងដូច្នោះដែរ ។ ពួកយៀកកុងបានជ្រៀតចូលពេញស្រុក រហូតដល់លើគ្រែលោកសីហនុ ។ សេដ្ឋកិច្ចដាំដូងដល់ថ្នាក់ «វិនាសក្ស័យទុន» ។ ដល់ដើមឆ្នាំ១៩៧០ លោកសីហនុក៏នាំប្រពន្ធនិងកូនរត់ចោលស្រុកតែម្តងទៅ ។

ក៏ប៉ុន្តែរឿងដ៏អកុសលជាងនេះទៅទៀតនោះ, នៅពេលដែលប្រជាពលរដ្ឋខ្មែរ កំពុងនាំគ្នាបណ្តេញខ្មាំងឈ្លានពានយួនចេញពីទឹកដី លោកសីហនុនិងប្រពន្ធដ៏ឆ្នើមរបស់គាត់ ក៏នាំគ្នាហក់ទៅនៅខាងសត្រូវរបស់ជាតិ រួចពន្យុះសត្រូវនោះឲ្យលើកទ័ពទឹងចូលមកវាយប្រហារកាប់សម្លាប់លួចប្លន់ជាតិឯងស្ទើរពាយអស់ពីនគរ ។ ម្ល៉ឹងហើយគាត់នៅមិនស្កប់ចិត្តទៀត... ពេលកងទ័ពខ្មែរក្រហមរបស់គាត់ ទទួលបានជ័យជំនះលើរបបសាធារណរដ្ឋខ្មែរ (ថ្ងៃ១៧មេសា១៩៧៥) លោកសីហនុក៏ឡើងធ្វើជាប្រមុខរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ របបនេះក៏ប្រព្រឹត្តអំពើសម្លាប់រង្គាលយ៉ាងឃោរឃៅព្រៃផ្សៃ ទៅលើពលរដ្ឋខ្មែរអស់ចំនួនជិត៣លានថែមទៀត ។

ដល់ដូច្នេះទៅ... ចំពោះយើង... យើងមើលឃើញថា អ្នកម្នាងម៉ូនិក គឺជា «ស្រីចង្រៃឧត្បាត» ដែលនាំឲ្យជាតិលិចលង់ ។ លោកសីហនុក៏ជាផ្នែកដ៏ធំនៃការទទួលខុសត្រូវផងដែរ។ បើគ្មានលោកសីហនុនិងគ្មានអ្នកម្នាងម៉ូនិកទេ ស្រុកខ្មែរប្រហែលមិនធ្លាក់ដល់ថ្នាក់នេះឡើយ ។ យើងមិនដឹងថា តើកម្មពៀរអ្វីស្រុកយើង បានជាត្រូវជួបប្រទះអ្នកទាំងពីរតាមព្យាបាទពុំចេះចប់ពុំចេះហើយយ៉ាងដូច្នេះ ? ។

ពេលថ្មីៗកន្លងមកនេះទៀត គ្រាន់តែរឿងអ្នកម្នាងចង់ឡើងសោយរាជ្យសោះ លោកសីហនុត្រូវធ្វើទុក្ខបុកម្នេញស្រុកទេស ឡើងវិលមុខគ្រប់គ្នា បន្ថែមពីលើគំនរបញ្ហាដ៏ធ្ងន់ធ្ងររាប់ម៉ឺនជំពូកដែលជាតិត្រូវប្រឈមមុខតទល់ ។ លោកសីហនុគាត់ចេញអស់ក្បាច់ ទំរាំផុតពីអ្នកម្នាងឆ្លងបានទៅដល់កូនឡើងស្នងរាជ្យបន្ត ។

បានប៉ុណ្ណឹងហើយនៅទាន់ស្កប់ចិត្តទៀត អ្នកម្នាងនៅតែរំអុកម្ជុលភ្លៅលោកសីហនុដដែល ។ គាត់ចង់ឡើងធ្វើជា «រាជានុសិទ្ធិ» និងចង់ឲ្យចៅស្រីទាំងពីរ (កូនស្រីរបស់ទ្រង់នរិន្ទ្រាពង្ស) អាចឡើងសោយរាជ្យបន្តពីទ្រង់សីហមុនី ។ ទ្រង់នរិន្ទ្រាពង្ស ជាកូនប្រុសពៅរបស់អ្នកម្នាងម៉ូនិច និងត្រូវជាប្អូនបង្កើតរបស់ទ្រង់សីហមុនី ។ កាលនៅរស់ ពេលលោកសីហនុចូលស្រុកខ្មែរឆ្នាំ១៩៧៥, ទ្រង់នរិន្ទ្រាពង្ស ជាសមាជិកសកម្មនៃកម្ពុជាប្រជាធិបតេយ្យ។ គេហៅទ្រង់ថា«មិត្តរិនៗ»។ ទ្រង់ក៏ត្រូវពួកមេខ្មែរក្រហមគ្រោងសម្លាប់ចោលដែរ តែបានត្រូវអន្តរាគមន៍ពីលោកម៉ៅ-សេទុង ទើបរស់ជីវិត ។ ទ្រង់បានស្លាប់ទៅហើយនៅក្រុងប៉ារីសកាលពីឆ្នាំ២០០៣ ដោយបន្សល់ទុកនៅកូនស្រី២នាក់គឺ ៖ ម្ចាស់ក្សត្រីនរោត្តម-ស៊ីមូណារីន <ណានិក> កើតថ្ងៃទី២៣កញ្ញា១៩៨៣ និងម្ចាស់ក្សត្រីនរោត្តម-មុនីនុ កើតថ្ងៃទី១៨មិនា១៩៨៧ ។ ប្រពន្ធរបស់ទ្រង់នរិន្ទ្រាពង្ស គឺនាងស៊ីន្ទួន ត្រូវជាក្មួយស្រីរបស់ឃុនព្រះម្នាងកេសរ ម៉ាលី ឯកណាត។៊

សូមអញ្ជើញអានអត្ថបទរបស់លោកសីហនុនៅក្នុងព្រឹត្តិប័ត្រ BMD

ចុះថ្ងៃទី២៩ធ្នូ២០០៤ ដែលមានខ្លឹមសារបកប្រែក្រៅផ្លូវការដូចខាងក្រោមនេះ ៖

«មហាក្សត្រថ្មីនៃកម្ពុជា (នរោត្តម-សីហមុនី) គឺជាទីស្រឡាញ់ គោរព និងកោតសរសើរយ៉ាងខ្លាំងក្លា នៃជនរួមជាតិរបស់ព្រះអង្គ (ជាពិសេសប្រជារាស្ត្រតូចតាច) ស្រីៗអ្នកស្រុកដ៏ជាទីស្រឡាញ់របស់យើងខ្លះចាប់ផ្តើមមានចិត្ត ប្រាថ្នាចង់ឲ្យព្រះអង្គរៀបការ ដើម្បីអាចជូនដល់ជាតិនូវស្តេចបន្តរាជ្យមួយអង្គ (Crown-Prince) ដែលមានឈាមជ័រពុំអាចប្រៀផ្ទឹមបាននៃមហាក្សត្រីមាតា នរោត្តម-មុនីនាថ-សីហនុ ។

ស្រីៗអ្នកស្រុកទាំងនេះនិយាយថា ៖ យើងស្រឡាញ់កូន, ចៅ, ចៅទួតរបស់សម្តេចឪ ។ ហេតុដូច្នេះ នៅក្រោយរាជ្យមហាក្សត្រសីហមុនីដែលយើងបន់ស្រន់ឲ្យស្ថិតនៅយូរអង្វែងតទៅ, យើងពិតជាចង់បានព្រះមហាក្សត្រ ដែលនឹងបន្តពីព្រះអង្គ ដែលមានឈាមជ័រនៃសម្តេចម៉ែមុនីនាថដ៏ជាទីស្នេហារបស់យើង ។

❑

ដល់មហាក្សត្រសីហមុនីគ្មានបំណងចង់បានប្រពន្ធយ៉ាងដូច្នេះ ដំណោះស្រាយតែមួយគត់ ដើម្បីបំពេញចិត្តប្រជារាស្ត្រតូចតាចរបស់យើង គឺមានតែ«ការរៀបចំ»ក្មួយស្រីដ៏ស្រស់បំព្រង និងមានការរៀនសូត្រចេះដឹងល្អនៃមហាក្សត្រសីហមុនី និងត្រូវជាចៅស្រីរបស់មហាក្សត្រីមាតាមុនីនាថ (គឺម្ចាស់ក្សត្រីនរោត្តម-នរិន្ទ្រពង្ស-ណានិក និង មុនីនុ... ណានិក = នរិន្ទ្រពង្ស-ម៉ូនិក... មុនីនុ = ម៉ូនិកនិងសីហនុ) នឹងត្រូវជ្រើសរើស (ក្នុងពេលអនាគតយូរទៅមុខទៀត) អង្គមួយណាក៏បានដែរ ឲ្យឡើងសោយរាជ្យជាស្តេចស្រីនៃកម្ពុជា ដោយធ្វើការប្រែរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣របស់យើង ដែលនៅតែប្រកាន់ច្បាប់ហាមមានស្តេចស្នងជាស្រីឡើងគ្រប់គ្រងព្រះរាជបល្ល័ង្កនៃរាជាណាចក្រកម្ពុជា » ។

ឈ្មោះចៅស្រីដែលលោកសីហនុហៅ ខុសគ្នាពីឈ្មោះដែលបានសរសេរនៅក្នុងសៀវភៅរបស់លោក Corfield (p.108) ។

សំណេររបស់លោកសីហនុនេះ វាធ្វើឲ្យយើងមើលឃើញថា លោកសីហនុគាត់ពឹតតែពីយកចិត្តប្រពន្ធចុង(ម៉ូនិក)របស់គាត់ប៉ុណ្ណោះ ។ គាត់ធ្វើមើលតែ គាត់អត់មានកូនប្រុសឯណាមួយគ្រាប់ទៀតអញ្ចឹង ។ ពួកកូនបងៗដូចជាទ្រង់យុវនាថ, ចក្រពង្ស និងព្រះអង្គម្ចាស់ដទៃទៀតខាងខ្សែ<ស៊ីសុវត្ថិ> សុទ្ធតែជា «អង្គម្ចាស់ស្វា» ទាំងអស់ ។ គឺគាត់គិតថា មានតែឈាមគាត់ជាមួយម៉ូនិកទេ ទើបជាឈាមថ្លៃថ្នូរ ហើយសក្តិសមឡើងសោយរាជ្យលើនគរកម្ពុជា ។ លោកសីហនុនឹងម៉ូនិកខ្វល់តែប៉ុណ្ណឹងឯង ត្រង់រាស្ត្រវេទនាខ្លោចផ្សារឯណា បញ្ហានគរបែបណា គាត់អត់ខ្វល់ឡើយ ។

កង្វះព្រហ្មវិហារធម៌ជា«ឪគេ» លោកសីហនុបានធ្វើម្តងរួចមកហើយកាលពីពេលថ្មីៗកន្លងមកនេះ គឺគាត់បង្ខំឲ្យក្រុមប្រឹក្សាព្រះរាជបល្ល័ង្កជ្រើសរើសយកទ្រង់សីហមុនី តាមដែលគាត់និងប្រពន្ធគាត់ចង់បាន ។

អ្វីដែលប្រពន្ធចុងរបស់គាត់ (អ្នកម្នាងម៉ូនិក) ស្រេកឃ្លានចង់បាន គាត់ផ្គាប់ចិត្តភ្លាម រហូតដល់ទៅចង់ឲ្យគេកែប្រែរដ្ឋធម្មនុញ្ញ សំរាប់តម្រូវតាមទៀតផង ។

គាត់ធ្លាប់ជេរហ៊ុន-សែននិងរណឫទ្ធិថា ធ្វើធម្មនុញ្ញ«កញ្ចប់»ដើម្បីបង្កើត«រដ្ឋាភិបាលកញ្ចប់» ។ ក៏ប៉ុន្តែនៅពីក្រោមតុ គាត់លួចបញ្ចេញ«រាជក្រឹត្យ» ទទួលស្គាល់ធម្មនុញ្ញនិងរដ្ឋាភិបាលកញ្ចប់នោះ ព្រមទាំងត្រាស់ចាត់តែងតាំងហ៊ុន-សែន ឲ្យឡើងធ្វើជានាយករដ្ឋមន្ត្រីថ្មីយ៉ាងរំភើយ ។ ដល់មកឥឡូវនេះ គាត់ក៏ចង់ធ្វើដូចគ្នាដែរ ។

គាត់ដើរល្បិច «ចូលរ៉ុំគ្រែត» ពីមុខតំណែង «មហាក្សត្រ» ដើម្បីបង្ខំគេធ្វើច្បាប់ក្រុមប្រឹក្សារាជបល្ល័ង្ក ។ គាត់ពុំបានទុកឲ្យក្រុមប្រឹក្សារាជបល្ល័ង្កនេះអនុវត្ត«ច្បាប់» ដែលគេទើបបង្កើតនៅក្តៅស្រួយខ្វោកនោះទេ គាត់បែរជាបង្ខំឲ្យគេលើកកូនរបស់អ្នកម្នាង ឡើងធ្វើជាស្តេចស្នងទៅវិញ ។ គាត់បំពានច្បាប់ ម្តងហើយម្តងទៀត និងគ្មានការខ្មាស់អៀន ព្រមទាំងគ្មានការទទួលខុសត្រូវអ្វីទាល់តែសោះ ។

មានអ្នកតាមដានព្រឹត្តិការណ៍ខ្លះបានឲ្យយោបល់ថា មូលហេតុដែលបណ្តាលឲ្យលោកសីហនុប្រញាប់ប្រញាល់បង្ខំចិត្តត្រូវធ្វើទាំងទទឹងទទែងដូចខាងលើនេះ ជាសញ្ញាឲ្យដឹងថា គាត់កំពុងមានបញ្ហាផ្នែកសុខភាពធ្ងន់ធ្ងរណាស់ និងកំពុងតែដឹងខ្លួនថាមិនអាចមានជីវិតរស់នៅយូរតទៅមុខឡើយ ។ ហេតុដូច្នេះ អ្នកម្នាងម៉ូនិកក៏ឆ្លៀតឱកាសអូសទាញយកផលប្រយោជន៍ពីប្តី តាមដែលអាចធ្វើទៅបាន ។

ក៏ប៉ុន្តែចំពោះយើងវិញ... យើងសូមមិនជឿយ៉ាងនេះទាំងស្រុងទេ។ យើងជឿថា លោកសីហនុនេះគាត់មានល្បិចវាល់កញ្ជេ ជាពិសេសស្ទៀតផ្តេកផ្សំផ្គុល-រមួលផ្សំគ្រិច ។ គាត់មិនមែន«វង្វេងចាស់»ទេ តាមពិតគឺគាត់ឆ្កួតជាមួយម៉ូនិក តាំងពី៥០ឆ្នាំបា្លយមកម្ល៉េះ ។ គាត់វង្វេងដែរ តែវង្វេងចូល ។ ដូចជាវង្វេងទាមទារសុំឲ្យគេកែប្រែរដ្ឋធម្មនុញ្ញ ដើម្បីឲ្យគាត់បានរួចខ្លួនពីការទទួលខុសត្រូវសំខាន់ៗចំពោះជាតិ និងសុំទាមទារឲ្យចៅស្រីរបស់គាត់ បានឡើងសោយរាជ្យជាដើម ។ សាកល្បងឲ្យគាត់វង្វេងសុំកែប្រែរដ្ឋធម្មនុញ្ញ ពីមហាក្សត្រសោយរាជ្យនិងមហាក្សត្រចូលរ៉ុំគ្រែត «ពុំអាចនរណាបំពានបាន» ឲ្យទៅជា«គេអាចបំពាន»បានវិញលមើលមើល តើគាត់នឹងវង្វេងវង្វាន់បែបនេះដែរឬទេ (??) ។ មេឃាទៅ (!!)

បើពោលឲ្យចំទៅ... គឺគាត់ឆ្កួតនឹងម៉ូនិកទេតើ... ស្រីឆ្នាម្នាក់ដែលពោរពេញដោយការលោភលន់ពុំចេះស្កប់ស្កល់សោះ (!!) ។៚

# អំពីរដ្ឋប្រហារទម្លាក់ស្ដេចសីហនុ

## ដកស្រង់ចេញពីនិក្ខេបបទរបស់លោក ចៅ-សេងអួរ

## (La Représentation Khmère à l'ONU, Edition Pédone 1974 - Paris)

បកប្រែក្រៅផ្លូវការ

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី១ មករា ២០០៥

ចំពោះស្ដេចសីហនុហើយនិងក្រុមគាំទ្ររូបគាត់ នេះគឺជារដ្ឋប្រហារចំណែកពួកអ្នកកាសែត ដែលស្វះស្វែងរកពត៌មានអស្ចារ្យៗ ក៏និយាយតាមគ្នាថាជាអីចឹងទៅ ។ ក៏ប៉ុន្ដែគ្មាននរណាម្នាក់រំឭកផងសោះថា ៖

★ នៅថ្ងៃទី១០ សីហា ១៧៩២ រដ្ឋសភាជាតិបារាំងក៏បានធ្វើរដ្ឋប្រហារដូចគ្នាដែរ ដោយដកមុខតំណែងពីស្ដេចល្វីទី១៦ ព្រមទាំងយករូបស្ដេចបារាំងនេះ ទៅឃុំទុកនៅក្នុងវិហារ ជាមួយនិងក្រុមគ្រួសាររបស់គាត់ ។

★ នៅថ្ងៃទី២១ កញ្ញា ១៧៩២, សមាជបដិវត្តន៍បារាំង (La Convention) ក៏បានធ្វើរដ្ឋប្រហារមួយទៀត ដោយថ្លែងប្រកាសបំបាត់រាជានិយម ព្រមទាំងតែងតាំងសាធារណរដ្ឋ ។

ព្រឹត្តិការណ៍ទាំងពីរខាងលើនេះ ការទម្លាក់ស្ដេចល្វីទី១៦ និងការទម្លាក់ស្ដេចសីហនុ បានត្រូវធ្វើឡើង ដោយមានការជជែកវែកញែកពិភាក្សាគ្នានៅក្នុងរដ្ឋសភាជាតិ ព្រមទាំងការបោះឆ្នោតសំរេចនៅចុងចប់, គឺពុំមែនមានន័យថា ជាលទ្ធផលនៃការឃុបឃិតដូចដែលពាក្យរដ្ឋប្រហារចង់សំដៅនោះទេ ។

❑

អ្នកសរសេរ (ស្ដេចសីហនុ) នៅក្នុង website របស់ខ្លួន នៃថ្ងៃទី៥ ធ្នូ ២០០៤ ថាប្រសិនបើទ្រង់រណឫទ្ធិ (កូនរបស់គាត់) ទទួលយល់ព្រមយករូបមន្តរបស់ហ៊ុន-សែន ក្នុងប្រការបង្កើតរដ្ឋាភិបាលចូលគ្នាទាំងពីរនាក់, គណបក្សរាជានិយមច្បាស់ជានឹងបាត់បង់កេរ្តិ៍និងកិត្តិយសនៅចំពោះមុខជនជាតិខ្មែរ និងជនបរទេសទាំងអស់ជាពុំខានឡើយ ។ រឿងនេះជារឿងធម្មតាពេកណាស់ ប្រសិនណាបើគេគិតអំពីអំពើរំលោភ (ឧក្រឹដ្ឋកម្ម) រាប់មិនអស់ ដែលមិនបានទទួលទោសពិន័យអ្វីសោះ ក្រោមរបបរបស់ហ៊ុន-សែន ។

ក៏ប៉ុន្ដែ កាលពីថ្ងៃទី៥ ធ្នូ ២០០៤, គាត់ (ស្ដេចសីហនុ) បានថ្លែងជាបន្ថែមថា ៖ «សេចក្ដីបញ្ជប់របស់ខ្ញុំ បើប្រៀបធៀបជាមួយនឹងខ្មោចរបបលន់នល់-សិរិមតៈ (១៩៧០-១៩៧៥) របបសព្វថ្ងៃរបស់សម្ដេចហ៊ុន-សែនអាចចាត់ទុកថា មានលក្ខណៈត្រឹមត្រូវដូចជាព្រះ» ។

ពោលដូច្នេះ, តើគាត់មានបានគិតទេថា កាលពីមុននិងក្នុងសម័យបោះឆ្នោតឆ្នាំ២០០៣, មានមនុស្សយ៉ាងតិចក៏១៤នាក់ដែរ ដែលគេបានពិឃាតដោយខុសច្បាប់ យោងតាមព្រឹត្តិប័ត្រនៃអង្គការមនុស្សធម៌ Amnesty International ចុះថ្ងៃ៣០ ធ្នូ ២០០៤ (ទំព័រទី៣) ដែលបញ្ជាក់ថាគ្មានឧក្រិដ្ឋជនម្នាក់ត្រូវរកឃើញ ឬក៏ចាប់បញ្ជូនខ្លួនទៅតុលាការផងឡើយ ។ ឥស្សរជនសំខាន់ជាងគេដែលទទួលរងគ្រោះគឺ ៖ ឧម-រ៉ាសាឌី, អ្នកតំណាងរាស្ត្រដែលត្រូវពិឃាតនៅខែកុម្ភៈ២០០៣ ។ ចៅក្រមសេដ្ឋា-ម៉ូនីបានត្រូវពិឃាតនៅខែមេសា២០០៣, លោកជួរ-ជេដ្ឋាឫទ្ធិ នាយករងនៃវិទ្យុ (?) បានត្រូវពិឃាតនៅខែតុលា២០០៣ ។ នាងកញ្ញាទូច-ស៊ុននិចបានគេចរួចពីការប៉ុនប៉ងប្រហារ ក៏ប៉ុន្ដែម្ដាយនាងដែលបានជួយការពាររូបនាង ក៏បានទទួលសេចក្ដីស្លាប់ជំនួស ។ លោកជា-វិជ្ជា នាយកនៃសហជីពម្នាក់ដ៏ល្បីឈ្មោះ បានត្រូវពិឃាតកាលពីថ្ងៃ២២មករា២០០៤ ។ នៅគ្រប់ប្រការទាំងអស់ ពួកឃាតករពុំបានទទួលទោសទណ្ឌកម្មអ្វីទាល់តែសោះ ។ តើនេះហើយឬលក្ខណៈត្រឹមត្រូវនៃរបបហ៊ុន-សែនដែលស្ដេចសីហនុលើកសរសើរថាល្អដូចព្រះនោះ ?

❑

## សភាពត្រឡប់ត្រឡិនរបស់សីហនុ

ស្ដេចសីហនុបានយល់ថា ពួកខ្មែរកម្ពុជាក្រោម (នៅដែនដីកូសាំង-ស៊ីនសព្វថ្ងៃនេះ) ឬពួក KKK (យោងតាមសំណេររបស់គាត់) បានត្រូវពួកបេរ៉េបៃតងអាមេរិកាំង ផ្ដល់ថវិកាយ៉ាងចាស់ដៃ ដើម្បីឲ្យបំផ្លិចបំផ្លាញនូវអ្វីៗដែលគេអាចបំផ្លិចបំផ្លាញបាន (អំពីសង្គមរាស្ត្រនិយមរបស់គាត់ និងប្រទេសកម្ពុជា) អំពីសមិទ្ធិ, សេដ្ឋកិច្ច, សាមគ្គីភាព និងសន្តិភាពរបស់ជនជាតិខ្មែរយើង ។

ក៏ប៉ុន្ដែ តើពួកណាដែលបានបំផ្លិចបំផ្លាញធនាគារជាតិកម្ពុជា នៅក្នុងឆ្នាំ១៩៧៥ ? មិនគឺពួកខ្មែរក្រហមទេឬ ដែលស្ដេចសីហនុបានរត់ទៅចុះចូលនៅក្នុងឆ្នាំ១៩៧០ មុននឹងក្លាយទៅជាប្រធានាធិបតី ព្រមជាមួយជាជនរងគ្រោះរបស់ពួកទាំងនេះ ដោយជាប់គុកនៅក្នុងវាំងរបស់ខ្លួនឯង, ក៏ប៉ុន្ដែតាមពិត គាត់បានហូបសុទ្ធតែប៉ាតេថ្លើមក្ងាន ដែលពួកខ្មែរក្រហមបានផ្គង់ផ្គើមយ៉ាងចាស់ដៃ (ដូចស្ដេចបានសារភាពនៅក្នុងសៀវភៅមួយដែលគាត់បានសរសេរដូច្នោះ) នៅពេលដែលប្រជាជាតិខ្មែរទាំងមូលកំពុងតែស្លាប់ដោយទូរភិក្ស អត់បាយក្រហាយទឹក នៅក្នុងរបបអធ៌មដ៏មហាកំរោលរបស់ពួកខ្មែរក្រហមដដែលនេះ ។

តើពួកណាដែលបានទប់ទល់នឹងការវាយលុករបស់យៀកកុងនិងយៀកណាមខាងជើងចូលភ្នំពេញ ជាមួយនិងពួកនិស្សិតក្មេងៗក្នុងរដ្ឋធានីកាលពីឆ្នាំ១៩៧០? មិនគឺពួកខ្មែរកម្ពុជាក្រោមដដែល (KKK) នេះទេឬ? ក៏ប៉ុន្ដែជាការពិតណាស់ កាលសម័យនោះ សីហនុបានរត់ចោលស្រុកខ្លួនឯង ហើយបានបោលទៅចូលខ្មាំងរួចទៅហើយ ។

❑

អំពីបូរណភាពទឹកដីនៃប្រទេសជាតិ, សីហនុបានទទួលស្គាល់ អំពីកង្វះសមត្ថភាពរបស់ខ្លួន (ទំព័រទី៦) ។ គាត់បានរំឭកអំពីមតិជនជាតិខ្មែរប្រុសស្រីជាច្រើន (ជាពិសេសពួកជនដែលមានសេរីភាពក្នុងការបញ្ចេញយោបល់ ដែលសព្វថ្ងៃរស់នៅអឺរ៉ុបខាងលិច, នៅស.រ.អា. នៅកាណាដានិងអូស្ត្រាលី) ដែលបានចោទរបបបច្ចុប្បន្នរបស់យើង ថាបានបណ្ដោយឲ្យវៀតណាម, ថៃ និងលាវ បង្ខិតព្រំដែន បណ្ដាលឲ្យខូចខាតដល់បូរណភាពទឹកដីរបស់យើងអស់មួយភាគ ។ ប៉ុន្ដែជាការផ្ទុយបញ្ច្រាស់ទៅវិញ គាត់ក៏បានស្រង់យកមតិមួយភាគ ដែលរស់នៅខាងក្នុងមាតុភូមិមកផ្សាយផងដែរ ដែលបានអះអាងថា បូរណភាពទឹកដីរបស់យើង ទាំងខាងដែនគោកនិងទាំងខាងដែនសមុទ្រ ពុំមានខូចខាតអ្វីសោះទេ ។ ហើយស្ដេចក៏បានបញ្ចប់ថា ៖ «យើងរស់ក្នុងទីងងឹតពន់ពេក គឺក្នុងសភាពអន្ធការទាំងស្រុង»...

នេះហើយគឺជាសេចក្ដីសារភាពដ៏ច្បាស់លាស់ អំពីកង្វះសមត្ថភាពរបស់គាត់ ។

ក៏ប៉ុន្ដែដើម្បីឃ្លាតចេញពីរាត្រីអន្ធការបែបនេះ, ស្ដេចគាត់បានសម្លឹងមើលឃើញតែមធ្យោបាយមួយប៉ុណ្ណោះ គឺស្នើសុំឲ្យប្រទេសទាំង៤ វៀត

ណាម, ថៃ, លាវ និងកម្ពុជា ឆែកពិនិត្យមើលគំនូសព្រំដែនឡើងវិញ ដោយយោងតាមផែនទីយ៉ៅធា ដែលកងទ័ពសហរដ្ឋអាមេរិកបានប្រើ ពីចន្លោះឆ្នាំ១៩៦៣ទៅ១៩៦៩... ពីព្រោះជាផែនទីមួយដ៏ល្អប្រសើរបំផុត បើតាមយោបល់របស់គាត់ (sic!) ។

ត្រង់កន្លែងនេះហើយ ដែលសភាពត្រឡប់ត្រឡន់របស់ស្ដេចសីហនុធ្វើឲ្យយើងនឹកចង់អស់សំណើច ។ ពីព្រោះគាត់ទើបនឹងបានសរសេរថ្មីៗនេះថា ពួកបេរ៉េបៃតងអាមេរិកាំង បានផ្គុងផ្ដើមគ្រឿងសាស្ត្រាវុធដ៏ក្រាស់ក្រែល ឲ្យពួកខ្មែរកម្ពុជាក្រោម (KKK) មកបំផ្លិចបំផ្លាញនូវអ្វីៗដែលអាចបំផ្លិចបំផ្លាញបាននៅប្រទេសកម្ពុជា ។ តើមានព្រះគុណាអស្ចារ្យអ្វីដែលអាចឲ្យគេយល់ថា ផែនទីដែលទាហានអាមេរិកាំងបានប្រើប្រាស់នេះ ជាផែនទីដ៏ត្រឹមត្រូវផងទៅ ?

កាលណាមនុស្សម្នាក់និយាយពាក្យបាយបិណ្ឌជាបាយបាត្រ ឡប់ៗបែបនេះ... តើគាត់នៅមានខួរក្បាលភ្លឺស្វាងដែរឬទេ ? តើគេអាចមានទំនុកចិត្តទៅលើស្ដេចនេះបានទៀតឬទេ ? ។

❏

## មនសិការរបស់ប្រជាពលរដ្ឋ

ជាការច្បាស់ណាស់ ក្នុងឋានៈជាជនជាតិខ្មែរ យើងមិនអាចពឹងពាក់លើនរណាទៀតក្រៅពីខ្លួនយើង និងទៅលើមនសិការរបស់យើងតែប៉ុណ្ណោះ ដើម្បីទប់ទល់នៅព្រំដែនរបស់យើង និងចលនាអន្តោប្រវេសន៍ដ៏សំបើមមហិមានៃពួកជនជាតិវៀតណាម ចូលមកក្នុងដែនដីរបស់យើង ដែលជំរុញមកដោយការទទួលស្គាល់នៃពួកដឹកនាំរបស់ពួកគេ ក្នុងទីរួមខេត្តទាំង១៨ដោយក្រសួងមហាផ្ទៃ, យើងគ្រាន់តែបានធ្វើសេចក្ដីតវ៉ាដោយឥតប្រយោជន៍...។ ពីព្រោះពួកអាជ្ញាធររបស់យើង គ្មានវីវរល់ឈឺក្បាលនឹងស្ដាប់ពាក្យរបស់យើងឡើយ ។ ពួកអ្នកទាំងនេះ បានធ្វើការចុះញ៉មរួចទៅហើយ ដូចតែព្រះបិតានៃព្រះរាជាណាចក្រកម្ពុជាផងដែរ...

យើងត្រូវគិតអំពីការរៀបចំ និងការដាក់ឲ្យមានដំណើរឡើងវិញនៃប្រជាជាតិយើងដោយខ្លួនយើងផ្ទាល់... ដើម្បីឲ្យមាតុប្រទេសរបស់យើងមាននិរន្តរភាពតទល់នឹងសត្រូវគ្រប់បែបយ៉ាង ។ ក្នុងប្រការនេះ យើងគ្រាន់តែប្រើសិទ្ធិនិងករណីយកិច្ច ដែលយើងមានប្រចាំរូបកាយ តាំងតែពីយើងបានប្រែក្លាយទៅជាប្រជាជនពេញលក្ខណៈតែប៉ុណ្ណោះ ។ ជាការពិតប្រាកដណាស់ យើងមិនទាន់មានសមត្ថភាពខាងផ្នែកសម្ភារៈ ដើម្បីអនុវត្តនូវអ្វីៗដែលជាឧត្ដមប្រយោជន៍សំរាប់ប្រជាជាតិយើងនៅឡើយទេ ។ ក៏ប៉ុន្តែយើងមានសិទ្ធិនឹងបញ្ចេញយោបល់អំពីការប្ដេជ្ញាចិត្តរបស់យើង ដែលធានាអះអាងពីច្បាប់អន្តរជាតិ ។

វាមិនទាន់យឺតពេលនៅឡើយទេ... តាមពិតពេលវេលាកំពុងតែមកដល់ហើយ ។

ខែធ្នូ ២០០៤,

ឌុក-រ៉ាស៊ី, ចៅ-សេងអួរ, អ្នកស្រីអ៊ុង-ប៊ុនហោ, លឹម-គឹមយ៉ា, អ៊ូ-ចល់

សម្លេងខ្មែរនៅបរទេស

# ទំនៀមទំលាប់ពូជពង្សស្តេចសីហនុះ ការក្បត់ជាតិជានិច្ចនិរន្ត

ដោយ លឹម-គឹមយ៉ា

ប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិច នរោត្តម-រណឫទ្ធិ ដែលជាប្រធានរដ្ឋសភា បានប្រកាសមានបំណងចង់ឲ្យគណបក្សរបស់ខ្លួន រំលាយចូលគ្នាជាមួយគណបក្សប្រជាជន ដើម្បីប្រជែងយកជ័យជំនះលើគណបក្សសម-រង្ស៊ី នាពេលបោះឆ្នោតឆ្នាំ២០០៨ ។

នៅពេលមុនរៀបចំធ្វើរដ្ឋាភិបាលថ្មីនេះ, កាលពីខែកក្កដាឆ្នាំ២០០៤ និងក្រោយពេលបោះឆ្នោតខែកក្កដាឆ្នាំ២០០៣ គណបក្សហ្វ៊ុនស៊ិនប៉ិចនិងគណបក្សសម-រង្ស៊ីបានចាប់ដៃគ្នាធ្វើរចនាសម្ព័ន្ធ«ចំណាងអ្នកប្រជាធិ-បតេយ្យ» ក្នុងវត្ថុបំណងកុំឲ្យហ៊ុន-សែនដឹកនាំរដ្ឋាភិបាលថ្មី ។ ប៉ុន្តែមិនបានប៉ុន្មានខែផង រណឫទ្ធិរត់ចោលគណបក្សសម-រង្ស៊ី ទៅចូលជាមួយគណបក្សប្រជាជនតែឯង ដើម្បីបង្កើតរាជរដ្ឋាភិបាលដឹកនាំដោយហ៊ុន-សែនដដែល ។ មិនត្រឹមតែប៉ុណ្ណោះ រណឫទ្ធិរកតែឱកាស ដើម្បីផ្តន្ទាទោសនិងកំចាត់សម-រង្ស៊ីចេញពីឆាកនយោបាយខ្មែរ ដូចដែលគេបានធ្វើទៅលើទ្រង់សិរីវុឌ្ឍ កាលពីឆ្នាំ១៩៩៥ ដែលគេបង្ខំឲ្យនិរទេសចោលស្រុកមួយរយៈពេលនៅបរទេសយ៉ាងដូច្នោះដែរ ។

បើយោងតាមអ្នកសង្កេតការណ៍នៅភ្នំពេញ បំណងរបស់រណឫទ្ធិគឺចង់បញ្ចេញភក្តីភាពរបស់ខ្លួនចំពោះគណបក្សប្រជាជន ដើម្បីរៀបចំរាជរដ្ឋាភិបាលថ្មីរួមគ្នានៅក្រោយពេលបោះឆ្នោតឆ្នាំ២០០៨ ។ ពួកអ្នកសង្កេតការណ៍បន្ថែមថា រណឫទ្ធិពិតជាដឹងយ៉ាងច្បាស់ថា គណបក្សទាំងពីរនេះពុំអាចច្របាច់បញ្ចូលគ្នាបានទេ ។

ហ៊ុន-សែនអត់និយាយអ្វីទាំងអស់ ។ តែហេង-សំរិន, ប្រធានកិត្តិយសគណបក្សប្រជាជនប្រកាសមិនយល់ស្របដោយនិយាយថា គណបក្សទាំងពីរនេះពុំអាចរំលាយចូលគ្នាបានទេ ពីព្រោះខុសគ្នាទាំងមនោគមវិជ្ជានិងអត្តសញ្ញាណ ពីព្រោះគណបក្សហ្វ៊ុនស៊ិនប៉ិចជាគណបក្សរាជានិយមតំណាងស្តេច ។

ពិតមែនហើយ គណបក្សហ្វ៊ុនស៊ិនប៉ិចដែលប្រជាពលរដ្ឋស្អប់ ប៉ុន្តែយល់ឃើញថា ខ្លួនចុះទន់ខ្សោយនៅក្នុងគណបក្ស ដែលទ្រង់សិរីវុឌ្ឍកំពុងតែឡើង ដែលទ្រង់កំពុងតែរៀបចំខ្សែរយៈតាំងពីច្រើនឆ្នាំមកហើយ ។ ជាពិសេស រណឫទ្ធិមិនសូវដែលចុះទៅជួបប្រជារាស្ត្រនិងក្រុមមូលដ្ឋានបក្សឡើយ រវល់តែទៅថ្នាក់ថ្នមប្រពន្ធចុងនិងកូនខ្ចីនៅស្រុកបារាំងដែលត្រូវជាអតីតប្រពន្ធរបស់រដ្ឋមន្ត្រីខ្លួន ។ តាមយើងយល់ ការដែលរណឫទ្ធិប្រកាសយ៉ាងនេះ គឺដើម្បីប្រមូលនិងស្ទង់មើលមតិសមាជិកខ្លួន ដែលកំពុងតែគាំទ្រទ្រង់សិរីវុឌ្ឍ ។

ហេតុអ្វី គណបក្សហ្វ៊ុនស៊ិនប៉ិចដែលជាគណបក្សរាជានិយមនិងតំណាងស្តេច និងឈ្នះឆ្នោតកាលពីឆ្នាំ១៩៩៣ ហើយត្រូវប្រជារាស្ត្រស្អប់ខ្លាំងម្ល៉េះ ? ។ គណបក្សនេះបាត់បង់សម្លេងបន្តិចម្តងៗ នៅពេលបោះឆ្នោតម្តងៗ គឺដោយសារតែនយោបាយនិងឫកពាមេដឹកនាំគណបក្សនេះធ្វើចំពោះប្រជារាស្ត្រ ។ យើងត្រូវរំលឹកថា កាលពីឆ្នាំ១៩៩៣ ប្រជាពលរដ្ឋនៅក្នុងជំរំតាមប្រទល់ដែនខ្មែរ-សៀម ដែលគ្នាជួយឲ្យគណបក្សនេះបានអំណាច ហើយគណបក្សក៏ភ្លេចគេចោល ។ ការក្បត់នេះគេមិនមែនធ្វើត្រឹមតែចំពោះប្រជាពលរដ្ឋនោះទេ គេធ្វើរហូតទៅដល់សមាជិកគេទៅទៀត ។

កាលពីឆ្នាំ១៩៩៨ នៅពេលបាតុកម្មប្រឆាំងនឹងការបន្លំលទ្ធផលឆ្នោត ស្តេចសីហនុបានក្បត់នឹងបាតុករ ទៅចូលដៃជាមួយហ៊ុន-សែន ។ បើមិនយ៉ាងដូច្នោះទេ ហ៊ុន-សែនច្បាស់ជាធ្លាក់ចេញពីអំណាច ដូចនៅប្រទេសអ៊ុយក្រែនថ្មីៗនេះ ។ នៅពេលនោះ មានតាំងពីព្រះសង្ឃត្រូវសុគតដោយសារក្រុមប៉ូលិសហ៊ុន-សែនវាយសម្លាប់ ។

កាលពីឆ្នាំ១៩៩៣ ក្រោយពីប្រកាសឈ្នះឆ្នោត គណបក្សហ្វ៊ុនស៊ិនប៉ិចនិងជាតិនិយម ស្តេចសីហនុក្បត់នឹងកូនដែលមានជ័យជំនះ បានប្រើកូនមួយទៀត (ចក្រពង្ស) ឲ្យធ្វើសេចក្តីប្រកាសកាត់ចែកស្រុក ដែលតំរូវឲ្យគណបក្សឈ្នះឆ្នោតរួមជាមួយគណបក្សប្រជាជនបំរើយួន ត្រូវធ្វើរាជរដ្ឋាភិបាលដើម្បីសីហនុខ្លួនឯងដើរតួ ។

កាលពីឆ្នាំ១៩៧០ រដ្ឋសភានៃរាជាណាចក្របានប្រកាសដកតំណែងសីហនុចេញ ដោយហេតុសីហនុក្បត់ជាតិ ។ សីហនុអត់ញញើតរត់ទៅចូលដៃជាមួយយួនហាណូយ មកឈ្លានពានប្រជាពលរដ្ឋនិងប្រទេសខ្លួនឡើយ ។ ជាពិសេស សីហនុជាប្រធានរបស់ពួកខ្មែរក្រហមប្រល័យពូជសាសន៍ ។

ហេតុដូចម្តេចបានជាពួកអស់នេះអត់ញញើតនឹងក្បត់ខ្មែរ ? ពួកក្រុមវង្សត្រកូលស្តេចគេយល់ថា ពួកគេជាមនុស្សប្រសិទ្ធិមានបុណ្យលើគេទាំងអស់ ។ ហើយគេយល់ថា ប្រជារាស្ត្រត្រូវការគេ មិនមែនពួកគេត្រូវការប្រជារាស្ត្រនោះទេ ។ ដោយយល់លើគំនិតនេះ ពួកគេមិនគោរពប្រជារាស្ត្រ ហើយពួកគេយល់ថា ពួកគេធ្វើអ្វីស្រេចនឹងក្បាលចិត្តពួកគេ ដោយពុំគិតផលប្រយោជន៍ប្រជារាស្ត្រ ។

បើយើងមិនរកចម្លើយដើម្បីបញ្ចប់អំពើក្បត់របស់ពួកអស់នេះទេ ប្រទេសយើងពុំអាចរកឃើញសន្តិភាពនិងសេរីភាពបានឡើយ ។ រឿងនេះស្រួលសោះ គឺគ្រាន់តែយើងធ្វើឲ្យពួកគេដឹងថា បើពួកអស់នេះក្បត់នឹងប្រយោជន៍ស្រុក គឺយើងឈប់គាំទ្រ ហើយបើអាចធ្វើកើត គឺយើងត្រូវកាត់ទោសពួកអស់នេះ ។ យើងមិនត្រូវគាំទ្រដោយងងឹតងងល់ ដើម្បីតែប្រយោជន៍កំទិចកំទីនោះឡើយ ។

# Tradition de la dynastie Sihanouk : La trahison perpétuelle

Norodom Ranariddh, président du Parti Royaliste FUNCINPEC – partenaire du PPC - et président de l'Assemblée Nationale, fait savoir qu'il voudrait que son parti fusionne avec le PPC pour battre le parti de Sam Rainsy aux élections de 2008. Avant la formation du gouvernement actuel en juillet 2004 et après des élections en juillet 2003, le FUNCINPEC et le Parti de Sam Rainsy avaient formé une "Alliance des démocrates", qui avait exclu toute reconduction de Hun Sen à la tête d'un gouvernement de la troisième législature de la nouvelle monarchie. Enfin, Ranariddh a abandonné son allié, Sam Rainsy, et est allé tout seul pour former le gouvernement reconduit par Hun Sen. En plus il cherche toutes les occasions pour disqualifier ou expulser Sam Rainsy de la scène politique. Comme il avait fait avec son demi-oncle, le Prince Norodom Sirivuth, demi-frère de l'ex-Roi Norodom Sihanouk, ancien ministre FUNCINPEC, en 1995, qui était obligé de s'exiler pendant un certain temps à l'étranger.

D'après des observateurs à Phnom-Penh, l'intention de Ranariddh est de montrer la fidélité de son parti au PPC en vue de former un nouveau gouvernement de coalition en 2008. Ils ajoutent que le prince savait parfaitement que ces deux partis ne peuvent pas fusionner.

Hun Sen, homme fort du PPC, n'a rien déclaré, mais le président d'honneur de son parti, l'ancien président Héng Samrin, avait rejeté cette proposition en vue des élections de 2008. Il ajoute que « ces deux partis ne peuvent pas fusionner parce qu'ils n'ont pas les mêmes idéologies et d'identités. Le Funcipec est un parti royaliste et représente le Roi».

Certes, le FUNCINPEC est impopulaire auprès de la population, et en plus Ranariddh se sent affaibli dans son propre parti au profit de son demi-oncle Sirivuth qui a pris sa revanche, qui tisse des cellules partout dans le parti et dans les milieux populaires. Ranariddh n'a pas l'habitude de descendre auprès de la base et en plus il a consacré beaucoup de temps à sa maîtresse et à son nouveau fils, ex-épouse de son ministre, qui résident dans la région parisienne. Il a fait sa déclaration pour tester les positions des militants du parti et les récupérer au détriment de son demi-oncle.

Pourquoi le FUNCINPEC est-il impopulaire ? Pourtant il avait gagné les élections en 1993 et en plus il représente la monarchie. Il perd des voix à chaque élection à cause des politiques menées par ses dirigeants et ses comportements vis-à-vis à la population. Il faut se rappeler qu'en 1993, la population dans les camps de la frontière Khméro-Thaï, qui a porté le FUNCINPEC au pouvoir, n'était pas reconnaissante. Ce parti au pouvoir ne s'occupait pas du rapatriement et de son installation dans le pays.

La trahison des dirigeants de ce parti ne se limite pas à la population, mais s'étend aussi aux membres.

En 1998, pendant la protestation populaire contre le trucage des résultats des élections de la deuxième législature, le Roi Norodom Sihanouk a trahi les manifestants en volant au secours du PPC, Hun Sen était au pouvoir. Sinon la manifestation aurait balayé les dirigeants ex-communistes comme en Ukraine. Il y avait beaucoup de victimes, même dans les milieux religieux, pendant ces manifestations.

En 1993, après la déclaration de la victoire du FUNCINPEC et des nationalistes aux élections, Norodom Sihanouk avait trahi son fils qui avait gagné, en demandant à un autre fils, Chakrapong, de faire une déclaration de sécession, en obligeant le parti gagnant a appeler le PPC pour former le gouvernement pour que Sihanouk pût jouer un rôle.

Dans les années 1970, les Assemblées du Royaume l'avaient destitué pour raison de trahison, il n'avait pas hésité d'aller pactiser avec les Nord-Vietnamiens pour agresser son propre peuple et son pays. En plus il présidait les Khmers Rouges, auteurs du génocide.

Pourquoi ces personnes osaient trahir et trahiront encore les Cambodgiens ? La famille Royale s'est comportée comme des personnes sacrées au-dessus de tout. Ils pensent que le peuple a besoin d'eux, ce n'est pas eux qui ont besoin du peuple. Dans cet esprit ils ne respectent pas le peuple, ils pensent qu'ils pourraient faire comme ils l'entendent sans tenir compte des intérêts du peuple.

Si les Cambodgiens ne trouvent pas de remède pour faire cesser les trahisons des dirigeants, le pays ne retrouvera pas la paix et la liberté. Pourtant tout est simple, il faut qu'on fasse comprendre aux dirigeants que s'ils trahissent les intérêts du pays on retire son soutien, et si c'est possible qu'on les traduira un jour devant une cour de justice au lieu de les soutenir en espérant obtenir des miettes.

LIM Kim-Ya

ទន្លេរស្មី
សម្លេងខ្មែរនៅបរទេស

# សោកនាដកម្មខុសគ្នា

## រវាង<ស៊ូណាមី>មនុស្សបង្កើត នឹង<ស៊ូណាមី>បង្កឡើងដោយធម្មជាតិ

ដោយបណ្ឌិត ទិត-ណារញ្ញគិរី
(ប្រែសំរួលដោយ លី-ឌៀប)

បាតុភូតមហន្តរាយធម្មជាតិថ្មីៗនេះ ដែលគេហៅថា <ស៊ូណាមី> ឬ <ភ្នំរលកបង្កឡើងដោយការរញ្ជួយផែនដី> បានបំផ្លាញអាយុជីវិតមនុស្សស្លូតត្រង់យ៉ាងច្រើននៅក្នុងតំបន់អាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍ ធ្វើឲ្យខ្ញុំប្រមើគិតអំពីគ្រោះថ្នាក់ធម្មជាតិដ៏មហារន្ធឹអស្ចារ្យនេះ ។ ខ្ញុំពុំអាចជួយអ្វីបានទេ ក្រៅអំពីប្រៀបធៀបគ្រោះថ្នាក់ធម្មជាតិធ្វើឲ្យមានការខូចខាតដ៏ធំធេង ដែលមនុស្សលោកពុំអាចនឹកស្មានដល់ ទៅនឹងគ្រោះថ្នាក់ដែលកំពុងតែកើតមានឡើងនៅក្នុងប្រទេសកម្ពុជា ។ ហើយបើទោះបី សោកនាដកម្មដ៏ធ្ងន់ធ្ងរទាំងអស់នេះ បានធ្វើឲ្យរំជួលចិត្តទៅដល់មនុស្សគ្រប់វ័យគ្រប់ជាតិសាសន៍ និងគ្រប់ជំនឿសាសនា នៅក្នុងតំបន់អាស៊ីយ៉ាងណាក៏ដោយ ពន្លឺនៃសេចក្តីសង្ឃឹមខ្លះ ក៏បានចាប់ផ្តើមបង្ហាញរូបរាងមកហើយដែរ ។ ជាឧទាហរណ៍ ជំនួយដ៏មានចំនួនយ៉ាងធំធ្វើកពេទ្យ, ហិរញ្ញវត្ថុ និងសម្ភារៈ ក៏បានមកដល់ពីគ្រប់ជ្រុងជ្រោយនៃពិភពលោក ដូចគ្នាបានមកពីរដ្ឋាភិបាលព្រមទាំងឯកជននានាផងដែរ ។ នៅក្នុងកាលៈទេសៈនេះ ពួកបស្ចឹមប្រទេសជឿនលឿនធំៗ ក៏ដូចគ្នានឹងប្រទេសជប៉ុនដែរ បានចាប់ផ្តើមមិនមែនគ្រាន់តែផ្តល់ជំនួយដ៏ច្រើននិងការផ្គត់ផ្គង់សម្ភារៈប៉ុណ្ណោះទេ, ពួកគេបានពិនិត្យមើលក្នុងរយៈពេលវែង នៃការកសាងឡើងវិញចំពោះភូមិភាគដែលទទួលរងនូវមហន្តរាយធម្មជាតិនេះ ។ យោងតាមសេចក្តីប្រកាសពត៌មាន, ពួកប្រទេសជឿនលឿនបានសំរេចចិត្តរួចហើយ ផ្លាស់ប្តូរកម្មវិធីសងប្រាក់ជំពាក់ចំពោះពួកប្រទេសរងគ្រោះទាំងនេះ ហើយថែមទាំងផ្តល់ជំនួយរយៈពេលវែង ដើម្បីកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធឯកជន និងរដ្ឋាភិបាលទៀតផង ។

ជាការផ្ទុយទៅវិញ, ប្រទេសកម្ពុជាត្រូវបានរងប៉ះទង្គិចនឹង<ស៊ូណាមី> ដែលបង្កឡើងដោយមនុស្ស ចាប់តាំងពីអំឡុងចុងឆ្នាំ១៩៦០ ដោយគ្មានសេចក្តីសង្ឃឹមថា នឹងមានការផ្លាស់ប្តូរអ្វីឆាប់ឡើយ ។ សេដ្ឋកិច្ចកម្ពុជាបានស្ថិតនៅក្នុងលំនាំស្រុតចុះ ដោយគ្មានសេចក្តីសង្ឃឹមណាមួយថានឹងធ្វើឲ្យបានល្អប្រសើរឡើងវិញឆាប់ៗនេះទេ ទោះបីបានទទួលជំនួយអន្តរជាតិយ៉ាងសំបើមផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេស ដែលជាមធ្យមប្រហែល៦០០លានដុល្លារក្នុងមួយឆ្នាំៗ ចាប់តាំងពីឆ្នាំ១៩៩១មកក៏ដោយ ។ បច្ចុប្បន្ននេះ, យោងតាមសេចក្តីរាយការណ៍មួយចំនួន ធ្វើឡើងដោយស្ថាប័នជំនួយអន្តរជាតិធំៗ ដូចជាធនាគារពិភពលោក (World Bank) និងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF), ប្រទេសកម្ពុជាគឺជាប្រទេសដែលក្រីក្រតោកយ៉ាកជាងគេបំផុតនៅលើភពផែនដីនេះ ។ គេចង់ដឹងថា តើជំនួយហិរញ្ញវត្ថុនិងបច្ចេកទេសដ៏ច្រើនលើសលប់ទាំងអស់នេះ ទៅកន្លែងណាអស់ទៅ ?

នៅក្រោមការដឹកនាំរបស់ហ៊ុន-សែន, ភោគទ្រព្យធម្មជាតិរបស់ប្រទេសកម្ពុជា បានត្រូវគេបំផ្លាញតាមប្រព័ន្ធពុករលួយ, កុមារា-កុមារីគ្មានម្ហូបអាហារត្រឹមត្រូវ ហើយប្រព័ន្ធពុករលួយបានក្លាយទៅជាទម្លាប់នៃការរស់នៅទៅហើយ ។ គេគ្មានអំពើយុត្តិធម៌, គ្មានការទទួលខុសត្រូវ, ការគោរពសិទ្ធិមនុស្ស ហើយលទ្ធិប្រជាធិបតេយ្យស្ថិតនៅតែលើក្រដាស់ប៉ុណ្ណោះ ។

ថ្មីៗនេះ, នៅក្នុងបទសម្ភាសន៍មួយជាមួយកាសែតជប៉ុន, ហ៊ុន-សែន, ជនផ្តាច់ការខ្មែរបានស្តីបន្ទោសពិភពលោក ពុំបានជួយប្រទេសកម្ពុជាគ្រប់គ្រាន់ទេ បើយោងតាមសំដីរបស់គាត់ដែលនិយាយថា ជាប្រទេសទទួលរងគ្រោះធ្ងន់ធ្ងរខ្លាំងណាស់ ជាងពួកប្រទេសរងគ្រោះធម្មជាតិថ្មីៗដោយ<ស៊ូណាមី>នៅអាស៊ីខាងត្បូង និងនៅអាស៊ីអាគ្នេយ៍នេះទៅទៀត ។ ក្នុងដំណើរទស្សនកិច្ចទីក្រុងមួយជិតភ្នំពេញ, ជនផ្តាច់ការខ្មែរនិយាយថា ៖

«បើយើងប្រៀបធៀបការខូចខាតបង្កឡើងដោយ<ស៊ូណាមី> ទៅនឹងអំពើសម្លាប់រង្គាលនៅក្រោមរបបប៉ុល-ពត គឺនៅតិចជាង១០ភាគរយនៃការខូចខាតដ៏ធំធេងនិងការបាត់បង់អាយុជីវិត» ហ៊ុន-សែនពោលនៅក្នុងបុណ្យសម្ពោធទំនប់ទឹកមួយស្ថិតនៅក្រៅក្រុងភ្នំពេញ (Kyodo News) ។

នេះវាជាការធម្មតាពេកទៅហើយ, ហ៊ុន-សែនគាត់កំពុងតែធ្វើឲ្យក្រុមខ្មែរក្រហមក្លាយទៅជាខ្មោចព្រាយបិសាច ដើម្បីឲ្យខ្លួនគាត់និងចៅហ្វាយឃួនរបស់គាត់ ត្រូវគេមើលឃើញថាជាមនុស្សល្អ ។

ក៏ប៉ុន្តែការពិត ហ៊ុន-សែននេះគាត់គឺជាផ្នែកមួយនៃ<ស៊ូណាមី>ខ្មែរដែលបង្កឡើងដោយមនុស្ស ។ ហ៊ុន-សែនបានឡើងធ្វើជានាយករដ្ឋមន្ត្រីខ្មែរ តាំងពីពាក់កណ្តាលអំឡុងឆ្នាំ១៩៨០ម្ល៉េះ ។ មានតែគាត់ និងគឺជាគាត់ម្នាក់ឯងប៉ុណ្ណោះ ដែលបញ្ជាត្រួតត្រាទៅលើស្រុកទាំងមូល ដោយអំណាចផ្តាច់ការ ដោយគ្មានការហ៊ានប្រកួតប្រជែង ពីគណបក្សនយោបាយណាមួយ និងពីបុគ្គលណាមួយ តួយ៉ាងដូចជាស្តេចសីហនុជាដើម ។ ជាការផ្ទុយទៅវិញសោះ, ស្តេចសីហនុបានប្រើប្រាស់មុខមាត់របស់គាត់ក្នុងឆាកអន្តរជាតិ និងប្រជាប្រិយភាពរបស់គាត់ក្នុងចំណោមពួកអ្នកស្រែចំការខ្មែរ ផ្តល់ភាពស្របច្បាប់ដល់ហ៊ុន-សែននិងគណបក្សប្រជាជនកម្ពុជា តាំងពីពេលបានជួបគ្នាជាលើកទីមួយនៅឯស្រុកបារាំង ចាប់តាំងពីឆ្នាំ១៩៨៧មកម្ល៉េះ ។

( កកន ៖ ហ៊ុន-សែនកំពុងក្រអើតក្រអោងនឹងខ្លួនឯងពេកទេដឹង ។ តាមពិត អន្តរជាតិបានជួយខ្មែរជាង២ពាន់លានដុល្លារ សំរាប់រៀបចំការបោះឆ្នោតឆ្នាំ១៩៩៣ រួចហើយបានបន្តជំនួយជាមធ្យមជាង៥០០លានដុល្លារថែមទៀតជារៀងរាល់ឆ្នាំរហូតមក ។ ខ្មែរយើង គួរណាស់មានការទទួលខុសត្រូវ ហើយមូរដៃអាវនាំគ្នាធ្វើការកសាងស្រុកឡើងវិញ ។ ក៏ប៉ុន្តែគួរឲ្យអនិច្ចា ជំនួយទាំងអស់នោះ សំរាប់តែបំរើអំពើពុករលួយ និងអំណាចផ្តាច់ការរបស់ពួកជនផ្តាច់ការមួយក្តាប់តូចទៅវិញ ។ ស្រុកកាន់តែក្រទៅៗ រង់ចាំតែថ្ងៃដាច់ដង្ហើមស្លាប់ប៉ុណ្ណោះ ) ។

លទ្ធភាពហ៊ុន-សែនឱបក្រសោបទ្រព្យសម្បត្តិនិងអំណាចយ៉ាងលើសលប់នៅក្នុងស្រុកខ្មែរ បានដកស្រង់បង្ហាញឲ្យឃើញតាមរយៈការផ្តោះផ្តងទស្សនៈគ្នា រវាងជនជាតិខ្មែរ-អាមេរិកាំងពីររូប ដែលជាអ្នកមានពត៌មានគ្រប់គ្រាន់ បង្ហាញឲ្យឃើញនូវជំរុយរបស់ហ៊ុន-សែនក្តោបក្តាប់អំណាចនៅកម្ពុជា ដូចតទៅនេះ ៖

« Tom និយាយត្រូវណាស់ ។ តើគាត់បានលុយពីណាមកដើម្បីទៅសង់ផ្ទះដែលមានតម្លៃរាប់សិបលានដុល្លារ មិនត្រឹមតែផ្ទះនៅលើផ្លូវស

មុទ្រជាប់មាត់ទឹកប៉ុណ្ណោះទេ តែរហូតដល់បន្ទាយនៅតាខ្មៅ និងនៅវិមានឯករាជ្យ ហើយនិងប្រហែលនៅទីកន្លែងផ្សេងទៀត ក្នុងពេលដែលពួកគ្រូបង្រៀនបានទទួលប្រាក់ខែពី២០ទៅ២៥ដុល្លារប៉ុណ្ណោះក្នុង១ខែៗ ។

បើពួកប្រទេសធ្វើអំណោយ មិនធ្វើការត្រួតពិនិត្យមើលដោយប្រុងប្រយ័ត្នទៅលើប្រាក់ ដែលគេរំពឹងអភិវឌ្ឍន៍ដល់កម្ពុជាទេនោះ, ប្រជាពលរដ្ឋខ្មែរទាំងអស់នឹងត្រូវរងទុក្ខវេទនា ។ ក៏ប៉ុន្តែវាជាការអាក្រក់ពន់ពេកណាស់ ដែលមនុស្សភាគច្រើនត្រូវហ៊ុន-សែននិងពួកមនុស្សរបស់គាត់ធ្វើឲ្យភ័ន្តភាំង ។

គាត់រិះគន់ពួកគ្រូបង្រៀន ពីព្រោះមកពីគាត់ខ្លួនគាត់គ្មានការសិក្សារៀនសូត្រ ។

ដោយសេចក្ដីគោរពយ៉ាងខ្ពង់ខ្ពស់,

(BadBoy)

❑

ក្នុងអត្ថបទ ៖ «ហ៊ុន-សែនកំពុងសង់ផ្ទះតម្លៃរាប់លានដុល្លារលើឆ្នេរសមុទ្រកំពង់សោម»

តើគាត់បានលុយនេះពីណាមក ? នៅក្នុងពេលជាមួយគ្នា គាត់បានចោទប្រកាន់អង្គការសហប្រជាជាតិ ថាជាអ្នករៀបចំបាតុកម្មពួកគ្រូបង្រៀន ។ នេះគឺដល់ពេលវេលាហើយទេដឹង ដែលសហគមធ្វើអំណោយអន្តរជាតិ ចាប់ផ្ដើមធ្វើការងាររបស់ខ្លួន ដើម្បីឲ្យសមស្របទៅតាមឆន្ទៈរបស់ពួកប្រទេសដាក់ទាន ។

សហគមធ្វើអំណោយកំពុងតែដើរតួជាមួយរូបភាពទុរគតរបស់ខ្មែរ ដើម្បីប្រមូលយកនូវការគាំទ្រជាទូទៅ ។ ដល់ដូច្នេះ ពួកគេត្រូវផ្ដល់ប្រាក់នេះ ទៅឲ្យអ្នកណាមួយ និងធ្វើឲ្យមើលឃើញថា លុយបានចែកចាយយ៉ាងត្រឹមត្រូវ ទោះបីការចែកចាយនោះពុំសូវល្អក៏ដោយ ។ ពួកគេភ័យខ្លាចការបង្ហាញឲ្យឃើញនូវប្រាក់លើសពីសេចក្ដីត្រូវការណាស់ ពីព្រោះការងាររបស់ពួកគេ, ការធានាសន្តិសុខដល់ខ្លួនគេ អាស្រ័យទៅលើការអន្ទងរកប្រាក់អំណោយទាំងស្រុង ដូចគ្នាទៅនឹងក្រុមហ៊ុនដែលគេរំពឹងទៅលើការស្វែងរកដើមទុន សំរាប់ធ្វើវិនិយោគយ៉ាងដូច្នោះដែរ ។

ទោះបីក្នុងមុខជំនួញរកស៊ី គេមិនលេងល្បែងវិនិយោគឆ្កួតៗ ដូចរដ្ឋាភិបាលខ្មែរក៏ដោយ, មុខការរកស៊ីរបស់សហគមធ្វើអំណោយ ពិតជាត្រូវរងគ្រោះ បើប្រសិនណាគ្មានលុយចូលទេ ។ ដូច្នេះសហគមធ្វើអំណោយ ត្រូវតែបន្តរកសុំលុយគេតទៅទៀត ដែលយ៉ាងហោចណាស់ក៏អាចការពារនូវមុខតំណែងរបស់ពួកគេជាអ្នករដ្ឋបាលដែរ ។

ក៏ប៉ុន្តែ តើឯកជនឬប្រទេសធ្វើអំណោយនីមួយៗ ចង់ធ្វើវិនិយោគនៅក្នុងអំពើពុករលួយ, ជាមួយរដ្ឋាភិបាលលោភលន់ ដូចមាននៅក្នុងស្រុកខ្មែរឬ ? ពួកគេពិតជាពុំចង់ដូច្នេះឡើយ ។ ដូច្នេះ ជាមួយការបោះលុយនេះទៅឲ្យខ្មែរ, សហគមធ្វើអំណោយ ក៏ធ្វើឲ្យឃើញថាមានការជឿនលឿនកំពុងតែប្រព្រឹត្តទៅ បើប្រសិនយើងធ្វើទៅតាមគន្លង...។ ខ្ញុំគិតថាស្រុកហៃទី គឺជាឧទាហរណ៍របស់ពួកគេស្រាប់ ។

តាមពិតទៅ, ពួកគេកំពុងក្បត់ចំពោះកិច្ចការដែលពួកប្រទេសធ្វើអំណោយបានប្រគល់មកឲ្យពួកគេ ក៏ដូចគ្នាក្បត់និងប្រជាពលរដ្ឋខ្មែរផងដែរ ។ ប្រទេសដាក់ទានមានអនុភាពយ៉ាងខ្លាំងក្លាណាស់ តែពួកអ្នកចែកចាយដ៏ខ្ជះខ្ជាយរបស់ខ្លួន បានហុចអំណាចទាំងអស់នោះដាក់ទៅក្នុងមាត់ពុករលួយស្រេកឃ្លានពុំអាចអត់ទ្រាំបាន ដូចហ៊ុន-សែនជាដើម ។

វាជាការប្រសើរណាស់ បើសហគមធ្វើអំណោយអន្តរជាតិ តម្កល់លុយនេះនៅក្នុងបញ្ជីលើស (surplus) រហូតដល់លក្ខណពិតប្រាកដបានត្រូវទទួល ។ ធ្វើយ៉ាងដូច្នេះ ប្រហែលត្រូវនឹងឆន្ទៈពួកប្រទេសធ្វើអំណោយជាង ។ ហ៊ុន-សែនមុខត្រូវកែកុនយ៉ាងឆាប់រហ័ស កន្លែងដែលគាត់មានប្រាក់រាប់លានដុល្លារ សំរាប់សង់ផ្ទះនៅឆ្នេរសមុទ្រ ។ ខ្ញុំសន្និដ្ឋានថា គាត់បានប្រាក់នោះពីលើខ្នងប្រជាពលរដ្ឋខ្មែរ ដោយការលក់ដីរបស់របររបស់គាត់ទៅឲ្យជនបរទេស ។ ពួកមនុស្សរបស់គាត់ប្លន់លុយរាប់សិបលានដុល្លារ ក្នុងមុខងារជាអ្នកទាក់ទងភ្ញៀវ, មេក្រសួង, ពួកមន្ត្រីរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ជាអ្នកជំរិតយកលុយ តែមិនបង្កើតផលអ្វីសោះ ។ តើអ្វីទៅ ដែលផ្ដល់ឲ្យគាត់មានសិទ្ធិរិះគន់ពួកគ្រូបង្រៀន ដែលជាអ្នកបង្កើតផលខ្លះៗយ៉ាងពិតប្រាកដនោះ ?

Tom Y » ។

❑

ទៅលើរបៀបរស់នៅយ៉ាងស្ដ៏មស្តែរបស់ហ៊ុន-សែននេះ, គេត្រូវបន្ថែមផងដែរ អំពីគាត់រក្សាកងទ័ពចំនួនប្រហែល៨,០០០នាក់ (មួយកងវរសេនាធំ) ទុកធ្វើជាកងទ័ពផ្ទាល់ខ្លួន ។

ដូចយើងបានឃើញខាងលើក នូវការប្តូរទស្សនៈរវាងពលរដ្ឋខ្មែរ-អាមេរិកាំងពីររូប ថាហ៊ុន-សែនកំពុងរស់នៅជាជនមានប្រាក់រាប់លានដុល្លារ នៅក្នុងពេលដែលស្រុកខ្មែរទាំងមូល កំពុងស្ថិតនៅក្នុងភាពក្រីក្រតោកយ៉ាក និងក្ដីអស់សង្ឃឹម ។

គេត្រូវធ្វើសំនួរថា តើហ៊ុន-សែនដែលកើតមកជាអ្នកស្រុកក្រីក្រធ្វើដូចម្ដេច អាចប្រមូលបានភ័ព្វសំណាងផ្ទាល់ខ្លួនដ៏សំបើមម្ល៉េះក្នុងរយៈពេលយ៉ាងខ្លី ពេលប្រជាពលរដ្ឋខ្មែរភាគច្រើន កាន់តែក្រទៅៗនិងវេទនាកាន់តែខ្លាំងឡើងៗរៀងរាល់ថ្ងៃ ?

ចម្លើយទៅនឹងសំនួរនេះ មាននៅក្នុងឯកសារជាបន្តបន្ទាប់ទៅនេះ ៖

★ កម្ពុជាធ្វើដំណើរថយក្រោយ (១)

ថ្ងៃទី១៣ ធ្នូ ២០០៤

ដូចយើងបាននិយាយរួចហើយ (ក្នុងស៊េរីបការណ៍ខ្មែរ, ថ្ងៃទី៦ មករា ២០០៤ ៖ «សេចក្ដីពិស្ដារអំពីកិរិតសីលធម៌និងអនក្ខរកម្ម»), កម្ពុជាគឺជាស្រុកតែមួយគត់នៅក្នុងពិភពលោក ដែលចំណុចទាំង៣សំខាន់ៗជាងគេរបស់មនុស្ស (ភាពក្រីក្រ, សីលធម៌ និង អនក្ខរកម្ម) មានភាពធ្ងន់ធ្ងរក្រៃលែង ក្នុងរយៈពេល១០ឆ្នាំកន្លងមកនេះ, មានន័យថាស្រុកនេះកំពុងតែដើរថយក្រោយ ។

ភាពក្រីក្រ (ចំនួនភាគរយនៃពលរដ្ឋរស់នៅតិចជាង $0.75 ក្នុង១ថ្ងៃ)

- ១៩៩២ ៖ ៣៨%
- ១៩៩៨ ៖ ៣៦%
- ២០០៤ ៖ ៤៣%
- ២០០៥ (តាមការប៉ាន់ស្មាន) ៖ ៤៥%

កិរិតការស្លាប់នៃកុមារ (ក្រោយអាយុ៥ឆ្នាំ)

- ១៩៩០ ៖ ៩៧ / ១,០០០
- ២០០១ ៖ ១៣៨ / ១,០០០
- ២០០៣ ៖ ១៤០ / ១,០០០ (ប្រៀបធៀបទៅនឹង ២៣ / ១,០០០នៅស្រុកយួន និង ៥ / ១,០០០ នៅសិង្ហបុរី)

(Source: UNDP "Human Development Report" 2003; Unicef "Childhood Under Threat: The State of the World's Children 2005" Report)

កិរិតអនក្ខរកម្មនៃមនុស្សចាស់នៅឆ្នាំ២០០៣ (១៥ឆ្នាំឡើងទៅ)

- មិនចេះមើលអក្សរ (មិនស្គាល់អក្សរ) ៖ ៣៦%
- អនក្ខរកម្ម (ស្គាល់អក្សរខ្លះតែមិនចេះអាននិងសរសេរត្រឹមត្រូវ) ២៧%
- កិរិតសរុបមនុស្សចាស់មិនចេះអក្សរ ៖ ៦៣% ប្រៀបធៀបទៅនឹងចំនួនតិចជាង ៦០% កាលពីឆ្នាំ១៩៩០ ។

(Source: UNDP; Cambodian Ministry of Education)

ស្ថានភាពនៃកូនក្មេងខ្មែរ (១)

- ១៨ភាគរយនៃទារកខ្មែរកើតនៅក្នុងថ្ងៃនេះ   នឹងស្លាប់ទៅវិញមុនទៅដល់អាយុ៥ឆ្នាំ ។
- ទារកស្ទើរតែម្នាក់ក្នុង១០នាក់ កើតនៅក្នុងស្រុកខ្មែរ ពុំអាចរស់នៅមានជីវិតទៅដល់ខួបទី១របស់ខ្លួនឡើយ ។
- ទារកខ្មែរចំនួន ៦០,០០០ទៅ៦៥,០០០នាក់ (អាយុក្រោម១ខួប)ត្រូវស្លាប់រៀងរាល់ឆ្នាំ ដោយសារម្ហូបអាហារមិនល្អឬជម្ងឺ ដែលគេអាចបង្ការឬព្យាបាលបាន ។
- ៤៥ភាគរយនៃកុមារខ្មែរ មានម្ហូបអាហារមិនល្អ
- ៥៤ភាគរយនៃកុមារខ្មែរ ពុំមានការធំធាត់
- ៦៦ភាគរយនៃកុមារខ្មែរ ពុំមានលទ្ធភាពទទួលទានទឹកស្អាត
- ២.២លាននាក់នៃកុមារខ្មែរ រស់នៅក្នុងសភាពក្រីក្រតោកយ៉ាក

(Source: UNDP, Unicef)

សូមអានសម្គាសន៍ទាំងមូលជាភាសាបារាំងនៅ ៖

http://www.norodomsihanouk.info/mes%2004/humour/1112hum1.htm

គឺជាការច្បាស់ពិតប្រាកដណាស់ អំពីសេចក្តីរាយការណ៍ដែលនិយាយថា ពេលហ៊ុន-សែននិងគណបក្សប្រជាជនកម្ពុជារបស់គាត់ មិនត្រូវភ្លេចរណប្ញទ្ធិហើយនិងពួកនៅជុំវិញសីហនុ ដែលកំពុងតែមានឡើងៗក្នុងខណៈភាគច្រើននៃប្រជាពលរដ្ឋខ្មែរ កំពុងស្ថិតនៅក្នុងភាពក្រីក្រ និងទុក្ខវេទនា ។

នេះហើយជាហេតុដែលធ្វើសហគមអន្តរជាតិ មានកាធ្មើយណាយក្នុងការផ្តល់ជំនួយសប្បុរសធម៌ហិរញ្ញវត្ថុនិងបច្ចេកទេសទៅកម្ពុជាដែលត្រួតត្រាដោយហ៊ុន-សែន ។ ដល់ដូច្នេះទៅ, មូលហេតុសំខាន់នៃស៊ូណាមីខ្មែរបង្កើតឡើងដោយមនុស្ស ត្រូវតែធ្លាក់ទៅក្នុងរង្វង់ការទទួលខុសត្រូវរបស់ហ៊ុន-សែន / សីហនុ / រណប្ញទ្ធិ ។ ដូចគេបានឃើញយ៉ាងងាយអំពីការវិភាគនៅខាងលើស្រាប់ហើយ គឺគេពុំងាយជួសជុល<ស៊ូណូមី>ខ្មែរដែលបង្កើតឡើងដោយមនុស្សបានទេ ពីព្រោះអ្នកដែលទទួលខុសត្រូវយ៉ាងសំខាន់នៃប្រជាពលរដ្ឋ ចំពោះមុខមហន្តរាយនេះ កំពុងស្ថិតនៅលើអំណាចនៅឡើយ ។៚

★★★ សូមអញ្ជើញអាន website របស់បណ្ឌិតទិត-ណារញ្ញគីរី ៖

http://mysite,verizon.net/vzerofo3b/welcometonaranhkirittith-personalsite